# សំណើប្រជាមតិ ការជួញដូរមនុស្ស។ ទោសបញ្ញត្តិ។ លក្ខន្តិកៈផ្តួចផ្តើម។
# 35

## ★ ទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 35 ★

បញ្ឈប់ការជួញដូរមនុស្ស—បាទ/ចាសលើសំណើប្រជាមតិ 35។

នៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ស្ត្រី និងកុមារដែលងាយរងគ្រោះត្រូវបានគេឃុំឃាំងប្រឆាំងទៅនឹងឆន្ទៈរបស់ពួកគេ និងត្រូវបានបង្ខំឲ្យចូលរួមក្នុងពេស្យាកម្មដើម្បីផលប្រយោជន៍ហិរញ្ញវត្ថុរបស់ក្រុមអ្នកជួញដូរមនុស្ស។ ជនរងគ្រោះជាច្រើន គឺជាក្មេងស្រីដែលមានវ័យត្រឹមតែ 12 ឆ្នាំប៉ុណ្ណោះ។

ការជួញដូរមនុស្ស គឺជាសហគ្រាសមួយក្នុងចំណោមសហគ្រាសឧក្រិដ្ឋកម្មដែលរីកលូតលាស់លឿនបំផុតនៅក្នុងពិភពលោក ហើយវាកំពុងតែកើតឡើងជាក់ស្តែងនតាមផ្លូវនានាក្នុងរដ្ឋកាលីហ្វ័រញ៉ា និងតាមប្រព័ន្ធអ៊ីនធឺណិតជាកន្លែងដែលក្មេងស្រីៗត្រូវបានទិញ និងលក់។

ការសិក្សាថ្នាក់ជាតិមួយបានផ្តល់ឲ្យរដ្ឋកាលីហ្វ័រញ៉ានូវចំណាត់ថ្នាក់អក្សរ "F" ទៅលើ ច្បាប់របស់ខ្លួន សម្រាប់ដោះស្រាយបញ្ហាការជួញដូរផ្លូវភេទកុមារ។

ហេតុនេះហើយ យើងត្រូវការសំណើប្រជាមតិ 35។

*បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 35 នឹង ៖*

- បង្កើនរយៈពេលដាក់ពន្ធធនាគារសម្រាប់អ្នកជួញដូរមនុស្ស ដើម្បីចាប់ពួកឧក្រិដ្ឋជនទាំងនេះឲ្យទទួលខុសត្រូវ។
- តម្រូវឲ្យអ្នកជួញដូរមនុស្សដែលមានទោសទាំងឡាយចុះបញ្ជីជាអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទដើម្បីទប់ស្កាត់បទល្មើសក្នុងពេលអនាគត។
- តម្រូវឲ្យអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទដែលបានចុះបញ្ជីទាំងអស់បង្ហាញគណនីអ៊ិនធឺណិតរបស់ពួកគេ ដើម្បីបញ្ឈប់ការកេងប្រវ័ញ្ចលើកុមារតាមអ៊ិនធឺណិត។
- តំឡើងថ្លៃផាកពិន័យពីអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទដែលមានទោស ហើយប្រើប្រាស់ថវិកាទាំងនេះសម្រាប់បង់ថ្លៃសេវាផ្សេងៗរបស់ជនរងគ្រោះដូច្នេះអ្នកដែលនៅរស់អាចកែលម្អជីវិតរបស់ពួកគេវិញបាន។

*សំណើប្រជាមតិ 35 ការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ។*

ជនរងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទជាច្រើន គឺជាក្រុមកុមារដែលងាយរងគ្រោះ។ ពួកគេព្រួយបារម្ភចំពោះអាយុជីវិតរបស់ពួកគេ និងត្រូវរងការរំលោភបំពានផ្លូវភេទ ផ្លូវកាយ និងផ្លូវចិត្ត។ ការិយាល័យស៊ើបអង្កេតសហព័ន្ធ (FBI) ទទួលស្គាល់ថាទីក្រុងចំនួន បី នៅក្នុងរដ្ឋកាលីហ្វ័រញ៉ាគឺ - ទីក្រុង Los Angeles, San Francisco និង San Diego - គឺជាតំបន់មានការជួញដូរផ្លូវភេទកុមារក្នុងដង់ស៊ីតេខ្ពស់។ ហេតុនេះហើយ ទើបយើងត្រូវការសំណើប្រជាមតិ 35 ដើម្បីការពារកុមារពីការកេងប្រវ័ញ្ច។

*សំណើប្រជាមតិ 35 ចាប់អ្នកជួញដូរមនុស្សឲ្យទទួលខុសត្រូវចំពោះបទល្មើសដ៏គួរឲ្យភ័យខ្លាចរបស់ពួកគេ។*

"ក្រុមអ្នកជួញដូរផ្លូវភេទសម្លឹងរកមើលអ្នកដែលងាយរងគ្រោះបំផុតនៅក្នុងសង្គមរបស់យើង។ ពួកគេក្លាយជាអ្នកមាន ហើយបន្ទាប់មកបោះបង់ជនរងគ្រោះរបស់ពួកគេចោល។ សំណើប្រជាមតិ 35 នឹងចាប់ឧក្រិដ្ឋជនទាំងនោះឲ្យទទួលខុសត្រូវ។ តាមការអនុម័តសំណើប្រជាមតិ 35 ពលរដ្ឋកាលីហ្វ័រញ៉ានឹងធ្វើសេចក្តីថ្លែងការណ៍មួយបញ្ជាក់ថាពួកយើងនឹងមិនអត់ឱនចំពោះការរំលោភបំពានផ្លូវភេទលើកូនចៅរបស់យើងឡើយ ហើយយើងគាំទ្រដល់ជនរងគ្រោះក្នុងបទល្មើសដ៏អាក្រក់នេះជានិច្ច។"

—Nancy O'Malley, Alameda ខោនធី មេធាវីមណ្ឌល និងអ្នកគាំទ្រសិទ្ធិជនរងគ្រោះជាតិ។

*សំណើប្រជាមតិ 35 ជួយបញ្ឈប់ការកេងប្រវ័ញ្ចកុមារដែលចាប់ផ្តើមតាមអ៊ិនធឺណិត។*

ប្រព័ន្ធអ៊ិនធឺណិតផ្តល់ឲ្យក្រុមអ្នកជួញដូរមនុស្សនូវមធ្យោបាយរក កុមារដែលងាយរងគ្រោះ។ សំណើប្រជាមតិ 35 តម្រូវឲ្យអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទដែលមានទោសផ្តល់នូវព័ត៌មានដល់អាជ្ញាធរអំពីវត្តមានអ៊ិនធឺណិតរបស់ពួកគេដែលនឹងជួយការពារកុមាររបស់យើង និងទប់ស្កាត់ការជួញដូរមនុស្ស។

*ក្រុមអ្នកអនុវត្តច្បាប់ធំៗបំផុតក្នុងរដ្ឋកាលីហ្វ័រញ៉ាជំរុញឲ្យមានការបោះឆ្នោតបាទ/ចាស លើសំណើប្រជាមតិ លេខ 35។*

"ខណៈអ្នកទាំងនោះស្ថិតនៅជួរមុខក្នុងការប្រឆាំងនឹងការជួញដូរមនុស្ស យើងជំរុញដោយទទូចឲ្យគាំទ្រទៅលើសំណើប្រជាមតិ 35 ដើម្បីជួយដល់ពួកយើងក្នុងការកាត់ទោសអ្នកជួញដូរផ្លូវភេទទាំងនោះ និងការពារជនរងគ្រោះដោយសារការកេងប្រវ័ញ្ចផ្លូវភេទ។"

— លោក Ron Cottingham ប្រធានសមាគមស្រាវជ្រាវមន្ត្រីរក្សាសន្តិភាពរដ្ឋកាលីហ្វ័រញ៉ាដែលតំណាងឲ្យសមាជិកសុវត្ថិភាពសាធារណៈចំនួន 64,000 នាក់មានប្រសាសន៍។

*ជនរងគ្រោះពីឧក្រិដ្ឋកម្ម និងអ្នកតស៊ូមតិរបស់ពួកគេជំរុញឲ្យបោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ លេខ 35។*

"សំណើប្រជាមតិ 35 នឹងជួយការពារកុមារពីអ្នកជួញដូរមនុស្សដែលស្វែងរកប្រាក់ចំណេញតាមរយៈការលក់ពួកគេនៅតាមដងផ្លូវ និងតាមអ៊ិនធឺណិត។"

— លោក Marc Klaas ជាអ្នកតស៊ូមតិរបស់ជនរងគ្រោះពីឧក្រិដ្ឋកម្ម និងជាឪពុករបស់ Polly Klaas ដែលត្រូវបានគេចាប់ជំរិត ហើយសម្លាប់ចោលនៅក្នុងឆ្នាំ 1993 មានប្រសាសន៍"

"កាលពីអាយុ 14 ឆ្នាំ ខ្ញុំបានរត់ចេញពីផ្ទះដែលកើតមានបញ្ហា ហើយបានធ្លាក់ចូលក្នុងកណ្តាប់ដៃរបស់អ្នកជួញដូរមនុស្សម្នាក់។ អស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំត្រូវបានគេជួញដូរ និងរំលោភបំពាននៅក្នុងអំឡុងពេលដែលខ្ញុំនៅជាកុមារនៅឡើយ។ ក្នុងនាមជាអ្នករស់រានម្នាក់ពីការជួញដូរ ខ្ញុំស្នើសុំដល់ពលរដ្ឋកាលីហ្វ័រញ៉ាទាំងអស់ឲ្យក្រោកឈរប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងបោះឆ្នោតគាំទ្រសំណើប្រជាមតិ 35 នេះ។

—Leah Albright-Byrd, អ្នកនៅរស់ពីការធ្វើចរាចរមនុស្ស

ការពារកុមារពីការកេងប្រវ័ញ្ចផ្លូវភេទ។ បញ្ឈប់ការធ្វើចរាចរមនុស្សខុសច្បាប់។

*បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ លេខ 35។ VoteYeson35.com*

**LEAH ALBRIGHT-BYRD**
អ្នកនៅរស់ពីការធ្វើចរាចរមនុស្ស

**MARC KLAAS,** ប្រធាន
មូលនិធិ KlaasKids

**SCOTT R. SEAMAN,** ប្រធាន
សមាគមនាយកប៉ូលិសកាលីហ្វ័រញ៉ា

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍គាំទ្រនៃសំណើប្រជាមតិ លេខ 35 ★

តាមពិតទៅ វិធានការដែលអះអាងថាផ្តោតគោលដៅទៅលើការជួញដូរមនុស្សនេះគំរាមកំហែងដល់ពលរដ្ឋស្លូតត្រង់ជាច្រើន៖

ប្រសិនបើសំណើប្រជាមតិ 35 ត្រូវបានអនុម័ត នោះអ្នកទាំងឡាយដែលទទួលការឧបត្ថម្ភថវិកាពីពេស្យាកម្មធម្មតា និងដោយព្រមព្រៀងគ្នាក្នុងចំណោមមនុស្សពេញវ័យដូចជា - កូនៗរបស់អ្នករកស៊ីផ្លូវភេទ ឪពុកម្តាយ ប្តី/ប្រពន្ធ ដៃគូនៅក្នុងផ្ទះជាមួយគ្នា មិត្តរួមបន្ទប់ ម្ចាស់ផ្ទះឈ្នួល ឬអ្នកដទៃទៀត-អាចត្រូវកាត់ទោសពីបទធ្វើជាអ្នកជួញដូរមនុស្ស ហើយប្រសិនបើពួកគេត្រូវបានកាត់ទោស នោះពួកគេនឹងត្រូវបង្ខំឲ្យចុះបញ្ជីជាអ្នកប្រព្រឹត្តបទ ល្មើសផ្លូវភេទអស់មួយជីវិត។

"កូនប្រុសរបស់ខ្ញុំ ដែលបានបម្រើប្រទេសរបស់យើងនៅក្នុងជួរយោធាសហរដ្ឋអាមេរិក ហើយឥឡូវនេះចូលរៀននៅមហាវិទ្យាល័យនោះអាចត្រូវបានលាបពណ៌ថាជាអ្នកជួញដូរមនុស្ស ហើយត្រូវចុះបញ្ជីជាអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទ ប្រសិនបើខ្ញុំឧបត្ថម្ភដល់គេនូវប្រាក់ដែលខ្ញុំរកបានតាមរយៈការផ្តល់សេវាផ្នែកផ្លូវភេទនោះ។"

—Maxine Doogan មានប្រសាសន៍។

ក្រៅពីធ្វើការជាមួយសហគមន៍អ្នករកស៊ីផ្លូវភេទដើម្បីបញ្ឈប់អ្នកជួញដូរមនុស្សពិតប្រាកដ ក្រុមអ្នកគាំទ្រស្ត្រីប្រឆាំងនឹងការរួមភេទដែលនិយមឆ្វេង និងក្រុមអភិរក្សសាសនាដែលនិយមស្តាំ ដែលគាំទ្រសំណើប្រជាមតិ 35 សង្ឃឹមថា អ្នកបោះឆ្នោតដែលបានស្តាប់ឮ "ការជួញដូរមនុស្ស" នឹងត្រូវគេបោកបញ្ឆោតឲ្យគាំទ្រយុទ្ធនាការឥតប្រយោជន៍របស់ពួកគេប្រឆាំងទៅនឹង "របរចំណាស់ បំផុតរបស់ពិភពលោក" តាមរយៈការដាក់ទោសឧក្រិដ្ឋបន្ថែមទៅលើមនុស្សទាំងឡាយដែលពាក់ព័ន្ធនឹងពេស្យាកម្មមនុស្សពេញវ័យដោយមានការព្រមព្រៀងគ្នានោះ។ ការអះអាងរបស់អ្នកគាំទ្រដែលថារដ្ឋកាលីហ្វ័រញ៉ា គឺជា "តំបន់មានដង់ស៊ីតេខ្ពស់" ពីព្រោះការជួញដូរនោះ គឺមានភាពដូចគ្នាដែលគួរឲ្យសង្ស័យទៅនឹងការអះអាងមិនត្រឹមត្រូវមួយចំនួន

ដែលធ្វើឡើងនៅកន្លែងផ្សេងទៀតដែរ ៖ *http://www.oregonlive.com/portland/index.ssf/2011/01/portland_child_sex_trafficking.html*

សំណើប្រជាមតិ 35 នឹងបង្កើតទំនួលខុសត្រូវគ្មានថវិកាថ្មីមួយសម្រាប់រដ្ឋរបស់យើង ចំពេលដែលរដ្ឋាភិបាលរដ្ឋកាលីហ្វ័រញ៉ាកំពុងតែស្ថិតក្នុងវិបត្តិសារពើពន្ធ ហើយទីក្រុងយ៉ាងច្រើនក៏បានប្រកាសក្ស័យធនរួចហើយដែរ។ នាយកប្រតិបត្តិដ៏មានស្តុកស្តម្ភម្នាក់បានឧបត្ថម្ភថវិកាលើសពី 90% នៃថវិកាបរិច្ចាគសម្រាប់យុទ្ធនាការសំណើប្រជាមតិ 35៖

*http://www.huffingtonpost.com/2012/07/07/californians-against-sexual-exploitation-act_n_1656311.html*

ប៉ុន្តែថវិកានេះនឹងមិនមានសម្រាប់ផ្គត់ផ្គង់ការពង្រឹងច្បាប់ឡើយ។ អ្នកជួញដូរដែលបង់ប្រាក់មានជំនឿចិត្តថា - ការរឹបអូសយកទ្រព្យសម្បត្តិមិនបានផ្តល់ថវិកាបង់គ្រប់សម្រាប់ "សង្គ្រាមប្រឆាំងគ្រឿងញៀន" ទេ ហើយក៏នឹងមិនផ្តល់ថវិកាគ្រប់គ្រាន់ដល់ "សង្គ្រាមប្រឆាំងពេស្យាកម្ម" ដែរ។

បោះឆ្នោត ទេ លើសំណើប្រជាមតិ 35!

**MANUAL JIMENEZ,** CFO
អ្នកផ្តល់សេវាសម្រើប ស្របច្បាប់,
កម្រោងអប់រំ, និងស្រាវជ្រាវ, Inc.

**NORMA JEAN ALMODOVAR**

**STARCHILD**





*ទឡ្ហីករណ៍បោះពុម្ពនៅក្នុងទំព័រនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយមិនត្រូវបានពិនិត្យមើលភាពត្រឹមត្រូវដោយទីភ្នាក់ងារជាផ្លូវការណាមួយឡើយ។*

## ★ ទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 35 ★

សំណើប្រជាមតិ 35 ខ្វះខាតមិនបានបំពេញតាមការសន្យារបស់ខ្លួន ហើយអ្នកបោះឆ្នោតគួរតែបញ្ជូនវាត្រឡប់ទៅធ្វើការពិចារណាឡើងវិញ។

ការដាក់ឲ្យទៅជាបទឧក្រិដ្ឋមិនបាននាំមកនូវការការពារឡើយ។

ប្រសិនបើវាត្រូវបានអនុម័ត រដ្ឋកាលីហ្វ័រញ៉ានឹងត្រូវសរសេរមូលប្បទានបត្រចំហថ្មីមួយផ្សេងទៀតទៅឲ្យអ្នកគាំទ្រសំណើប្រជាមតិ 35។ វិធានការបោះឆ្នោតដោយមិនគិតវែងឆ្ងាយនេះ គឺពឹងផ្អែកទៅលើនិយមន័យដ៏ទូលំទូលាយនៃពាក្យថា ការផ្តល់សេវាផ្លូវភេទ។ ក្នុងនោះមានដូចជា ឪពុកម្តាយ កូន មិត្តរួមបន្ទប់ ដៃគូរស់នៅក្នុងផ្ទះជាមួយគ្នា និងម្ចាស់ផ្ទះឈ្នួលរបស់អ្នករកស៊ីផ្លូវភេទទាំងឡាយត្រូវបានកំណត់ថា ជាអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទ។ គោលដៅពិតប្រាកដ គឺធ្វើយ៉ាងណាឲ្យមានលទ្ធភាពធ្វើការដកហូតទ្រព្យសម្បត្តិទុកជាប្រយោជន៍សម្រាប់ភ្នាក់ងារអនុវត្តច្បាប់ និងការមិនស្វែងរកប្រាក់ចំណេញ។ សំណើប្រជាមតិ 35 មិនមានការត្រួតពិនិត្យមើល និងការទទួលខុសត្រូវឡើយ។ ប្រការនេះនឹងបើកឲ្យមានការអនុវត្តដោយពុករលួយដូចដែលយើងបានឃើញពីមុនមកហើយនៅក្នុងការអនុវត្តប្រឆាំងនឹងគ្រឿងញៀន។ *http://www.contracostatimes.com/news/ci_20549513/defendant-cnet-corruption-scandal-gets-federal-prison-sentence*

ប្រសិនបើវាត្រូវបានអនុម័ត នឹងមានឥទ្ធិពលអាក្រក់បង្កគ្រោះថ្នាក់ទៅលើថវិកាជាតិ។ ច្បាប់នេះពឹងផ្អែកលើធនធាននានាដែលធ្វើឱ្យមនុស្សធំទៅជាឧក្រិដ្ឋជនពេលគេត្រូវបានចាប់ចងដោយសារពេស្យាចារដោយមិនរើសមុខនៅក្នុងកិច្ចប្រតិបត្តិសំងាត់ដែលធ្វើឡើងក្រោមការលាក់កំបាំងជាអ្នកសង្គ្រោះជាកុមារ។ *http://www.sfgate.com/default/article/Bay-Area-sweep-nets-child-prostitute-pimp-suspects-3661229.php*

ការស្រាវជ្រាវបង្ហាញថាស្ទើរតែគ្រប់យុវវ័យដែលត្រូវគេចាប់ដោយពេស្យាចារគឺមិនមាន មេបនទេ។ដូច្នេះគំនិតដែលថាច្បាប់នេះនឹងបង់ថ្លៃខ្លួនឯងគឺមិនមានការគាំទ្រដោយភ័ស្តុតាងទេ។ បាត់ក្មេងប្រុស៖ ការស្រាវជ្រាវថ្មីលុបបំបាត់ភាពជាតួយ៉ាង *http://www.riverfronttimes.com/2011-11-03/news commercial-sexual-exploitation-of-children-john-jay-college-ric-curtis-meredith-dank-underage-prostitution-sex-trafficking-minors/*

សំណើប្រជាមតិ 35 ពឹងផ្អែកទៅលើគោលនយោបាយគ្មានប្រសិទ្ធភាពដែលប្រើប្រាស់ការធ្វើឲ្យទៅជាបទឧក្រិដ្ឋធ្វើទៅជាមធ្យោបាយដើម្បីចាប់ខ្លួនក្មេងមិនទាន់គ្រប់អាយុទាំងអស់ ក៏ប៉ុន្តែបានហៅទង្វើនោះថាជា "ការជួយសង្គ្រោះ" ទៅវិញ។

Cheryl Overs ជាសមាជិកក្រុមផ្តល់ប្រឹក្សាអង្គការសហប្រជាជាតិខាងដោះស្រាយបញ្ហាការកេងប្រវ័ញ្ចផ្លូវភេទជាលក្ខណៈអាជីវកម្មលើកុមារ *http://www.plri.org/story/tackling-child-commercial-sexual-exploitation* *កុំពង្រីកពួកប៉ូលិសដែលបានបរាជ័យរួចទៅហើយនេះតទៅទៀត។* *http://www.traffickingpolicyresearchproject.org/*

ប្រសិនបើវាត្រូវបានអនុម័តរដ្ឋទំនងជាតំរូវឱ្យការពារច្បាប់នេះនៅក្នុងតុលាការពីព្រោះវាប្រហែលជានឹងត្រូវប្រឈមនឹងផ្លូវច្បាប់ដោយមកពីមានការចោទជាសំណួរជាច្រើន និងវាអាចជាមាត្រាអធមនុញ្ញភាពដោយរួមនូវនិយមន័យមិនច្បាស់លាស់ផ្ទុយពីរដ្ឋធម្មនុញ្ញនៃពាក្យ "ការជួញដូរមនុស្ស" រួមទាំង"បំណងចែកចាយរឿងអាសអាភាស" ដែលអាចជាអធមនុញ្ញភាពក្នុងការដាក់ទោសមានលក្ខណៈ "ឃោរឃៅ និងមិនធម្មតា" រួមទាំងរយៈពេលដាក់ពន្ធនាគារ និងប្រាក់ផាកពិន័យច្រើនហួសកម្រិតអាចជាការហាមឃាត់ផ្ទុយពីរដ្ឋធម្មនុញ្ញទៅលើសិទ្ធិរបស់ចុងចោទក្នុងការណែនាំភ័ស្តុតាងនៅក្នុងការជំនុំជម្រះក្តីការពារខ្លួន។

ច្បាប់នេះ នឹងតម្រូវឲ្យរដ្ឋចំណាយថវិកាបន្ថែមក្នុងចំនួនមិនជាក់លាក់: វានឹងបង្កើនបន្ទុកការងារបន្ថែមទៅលើនាយកដ្ឋានសាកល្បងដែលមានបន្ទុកការងារច្រើនលើសលប់ទៅហើយនោះ។ សូមពិចារណាទៅលើករណីរបស់ Jaycee Dugard និងទឹកប្រាក់ចំនួន $20,000,000 ដុល្លារ ដែលរដ្ឋកាលីហ្វ័រញ៉ា បានបង់ទៅឲ្យនាងសម្រាប់ការដែលមិនការពារនាង ប្រឆាំងនឹងជនប្រព្រឹត្តល្មើសផ្លូវភេទដោយហិង្សាម្នាក់។ កិច្ចការនេះនឹងតម្រូវឲ្យមានការហ្វឹកហ្វឺនដល់មន្ត្រីនគរបាលដើម្បីអនុវត្តខចែងបន្ថែមនៅក្នុងច្បាប់នេះ។ *http://www.sfbg.com/politics/2012/06/16/bringing-heat*

សំណើប្រជាមតិដែលណែនាំខុសនេះ ប្រើប្រាស់នូវការភ័យខ្លាចដែលគ្មានការពិតដោយបញ្ឆេះបញ្ឆោលអ្នកបោះឆ្នោតឲ្យធ្លាក់ទៅក្នុងការលេងល្បែងទាក់ទងនឹងប្រាក់ផាកពិន័យ និងថ្លៃសេវានានាក្នុងពេលអនាគត ដោយបង្វែរទិសធនធានដ៏ខ្សត់ខ្សោយរបស់រដ្ឋចេញឆ្ងាយពីកម្មវិធីអន្តរាគមន៍ផ្អែកសេវាសង្គមដែលមានស្រាប់។

ច្បាប់នានាកំពុងត្រូវបានអនុវត្ត *http://blog.sfgate.com/incontracosta/2012/06/25concord-police-assist-with-multi-agency-operation-targeting-child-prostitution/*

គោលនយោបាយដែលជាមូលដ្ឋាននៃសំណើប្រជាមតិ 35 នេះ ត្រូវបានបង្កើតឡើងនៅខាងក្រៅចំណោមប្រជាជនដែលរងផលប៉ះពាល់។ ក្រុមអ្នកគាំទ្ររង់ចាំទទួលផលប្រយោជន៍ហិរញ្ញវត្ថុ តាមរយៈការទទួលបានប្រាក់ខែដើម្បី "ផ្តល់សេវាផ្សេងៗ" ដល់អ្នករកស៊ីផ្លូវភេទដែលធ្វើការងារដោយព្រមព្រៀង។ អ្នករកស៊ីផ្លូវភេទទាំងឡាយមិនចង់ឲ្យគេបង្ខំឲ្យចាកចេញពីការងារតាមច្បាប់ព្រហ្មទណ្ឌឡើយ ហើយក៏មិនចង់ឲ្យគេបង្ខំឲ្យទទួលយកសេវាផ្សេងៗពីអ្នកគាំទ្រដែរ។ អ្នករកស៊ីផ្លូវភេទទាមទារឲ្យមានសំលេងដែរ។

សូមឱ្យច្បាស់។ ការធ្វើជាឧក្រិដ្ឋកម្មនៃពេស្យាចារគឺជាលក្ខខណ្ឌដែលអនុញ្ញាតឱ្យមានការកេងប្រវ័ញ្ច។ ចូរយើងជាជាងលើកឡើងអំពីបញ្ហានេះ។

បោះឆ្នោត ទេ លើនយោបាយបរាជ័យទាំងនេះ។

បោះឆ្នោត ទេ លើសំណើប្រជាមតិ លេខ 35។

**MAXINE DOOGAN,** ប្រធាន
អ្នកផ្តល់សេវាសម្រើប ស្របច្បាប់,
កម្រោងអប់រំ, និងស្រាវជ្រាវ, Inc.

**MANUAL JIMENEZ, CFO**
អ្នកផ្តល់សេវាសម្រើប ស្របច្បាប់,
កម្រោងអប់រំ, និងស្រាវជ្រាវ, Inc.

35

## ★ ការឆ្លើយបដិសេធលើទឡ្ហីករណ៍ប្រឆាំងនៃសំណើប្រជាមតិ លេខ 35 ★

*"ខ្ញុំមានអាយុត្រឹមតែ 10ឆ្នាំប៉ុណ្ណោះនៅពេលដែលខ្ញុំត្រូវបានកេងប្រវ័ញ្ចជាលើកដំបូងបង្អស់ដោយអ្នកជួញដូរម្នាក់។ ខ្ញុំបានរងការឈឺចាប់ពីការរំលោភបំពានអស់រយៈពេលរាប់ឆ្នាំក្នុងអំឡុងពេលដែលអ្នកជួញដូរនោះបានទទួលប្រាក់ចំណេញ។ សូមក្រោកឈរឡើងដើម្បីស្ត្រី និងកុមារដែលកំពុងត្រូវបានគេជួញដូរនៅតាមផ្លូវ និងតាមអ៊ិនធឺណិត។ សូមបោះឆ្នោតគាំទ្រសំណើប្រជាមតិ លេខ 35 ដើម្បីបញ្ឈប់ការជួញដូរមនុស្ស។" —Withelma Ortiz, អ្នករស់រានពីការជួញដូរមនុស្ស មានប្រសាសន៍ថា។*

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ លេខ 35 នឹងប្រយុទ្ធតបនឹងការជួញដូរមនុស្សនិងការកេងប្រវ័ញ្ចលើស្ត្រី និងកុមារ។

ការសិក្សាមួយថ្មីៗនេះបានផ្តល់ចំណាត់ថ្នាក់អក្សរ "F" ដល់រដ្ឋកាលីហ្វ័រញ៉ាសម្រាប់ច្បាប់ប្រឆាំងការជួញដូរផ្លូវភេទកុមារដែលមានភាពទន់ខ្សោយរបស់ខ្លួន។ ការិយាល័យស៊ើបអង្កេតសហព័ន្ធ (FBI) បានកំណត់ទីក្រុង San Francisco, Los Angeles និង San Diego ថាជាតំបន់ជួញដូរផ្លូវភេទកុមារក្នុងកំរិតខ្ពស់។

អាយុជាមធ្យមនៅពេលដែលក្មេងស្រីត្រូវបានគេជួញដូរលើកដំបូង គឺពី 12 ទៅ 14 ឆ្នាំ។ ក្មេងៗទាំងនេះគួរតែកំពុងគិតគូអំពីកិច្ចការសាលា របស់ពួកគេ មិនមែនគិតគូពីវិធីដើម្បីរស់រានក្នុងយប់មួយទៀតដែលកំពុងត្រូវបានគេលក់នោះទេ។

សំណើប្រជាមតិ 35 នឹងការពារកូនក្មេងនៅក្នុងរដ្ឋកាលីហ្វ័រញ៉ា ដោយបង្កើនការផ្តន្ទាទោសប្រឆាំងនឹងការជួញដូរមនុស្សធ្វើឲ្យអ្នកជួញដូរដែលបានជាប់ទោសត្រូវចុះបញ្ជីជាអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទ ហើយទាមទារឲ្យអ្នកប្រព្រឹត្តបទល្មើសផ្លូវភេទដែលចុះបញ្ជីទាំងអស់ត្រូវផ្តល់ព័ត៌មានដល់អាជ្ញាធរអំពីវត្តមានតាមអ៊ិនធឺណិតរបស់ពួកគេ ដើម្បីជួយការពារការជួញដូរមនុស្សតាមអ៊ិនធឺណិត។

សំណើប្រជាមតិ 35 ជួយជនរងគ្រោះឲ្យទាញជីវិតរបស់ពួកគេបាន មកវិញដោយបង្កើនការពិន័យប្រឆាំងនឹងការជួញដូរមនុស្ស និង តំកល់ថវិកាទាំងនេះសំរាប់សេវាជនរងគ្រោះ។

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 35 គឺត្រូវបានគាំទ្រដោយសម្ព័ន្ធដ៏ទូលំទូលាយ ដែលរួមមាន៖

- អ្នកគាំទ្រកូនក្មេងនិងជនរងគ្រោះ ដូចជាមូលនិធិ KlaasKids និងជនរងគ្រោះឧក្រិដ្ឋកម្មដែលរួមគ្នា
- អង្គការពង្រឹងច្បាប់រដ្ឋកាលីហ្វ័រញ៉ាដែលតំណាងឲ្យមន្ត្រីដែល មានឋានន្តរសក្តិនិងពង្រឹងច្បាប់ឯកសារចំនួនច្រើនជាង 80,000 នាក់
- អ្នករស់រានពីការជួញដូរមនុស្ស

បោះឆ្នោត បាទ/ចាស លើសំណើប្រជាមតិ 35 បញ្ឈប់ការជួញដូរមនុស្ស និងការកេងប្រវ័ញ្ចលើកុមារ។

**WITHELMA ORTIZ**
អ្នកនៅរស់ពីការធ្វើចរាចរមនុស្ស

**CARISSA PHELPS**
អ្នកនៅរស់ពីការធ្វើចរាចរមនុស្ស

**NANCY O'MALLEY**
មេធាវីមណ្ឌល ខោនធី Alameda